# បច្ចេកវិទ្យា និងវិស័យការងារ

បច្ចេកវិទ្យាបាននឹងកំពុងរីកចម្រើនកាន់តែខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ហើយបានជ្រៀតចូលទៅក្នុងសកម្មភាពសេដ្ឋកិច្ច-សង្គម ប្រៀបបានដូចជាសរសៃឈាម ភ្ជាប់ទំនាក់ទំនងរវាងកោសិកា គ្រប់ផ្នែក គ្រប់វិស័យនៃជីវភាពរស់នៅប្រចាំថ្ងៃ។ នៅក្នុងវិស័យការងារ ការជ្រៀតចូលនៃបច្ចេកវិទ្យា មិនត្រឹមតែអាចបង្កើតការងារថ្មីៗប៉ុណ្ណោះទេ តែវាក៏ផ្លាស់ប្តូរទម្លាប់ និងវិធីសាស្ត្របំពេញការងារផងដែរ ដែលទាមទារឱ្យកម្លាំងពលកម្មត្រូវពង្រឹងសមត្ថភាព ចំណេះ និងជំនាញផ្នែកឌីជីថលបន្ថែមទៀត។



# ការវិវត្តនៃការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងកន្លែងការងារ

**1960s:** បច្ចេកវិទ្យានៅពុំទាន់ត្រូវបានប្រើប្រាស់នៅកន្លែងធ្វើការនោះទេ។ បើទោះបីជា Dynamic Random-Access Memory (DRAM) ដែលជាបន្ទះឈីបកុំព្យូទ័រ ត្រូវបានរកឃើញតាំងពីឆ្នាំ 1967 ក៏ពិតមែន ប៉ុន្តែហាក់គ្មានឥទ្ធិពលអ្វីមកលើបណ្តាក្រុមហ៊ុនឱ្យចាប់យកវាមកប្រើប្រាស់ភ្លាមៗនោះទេ។ ខណៈពេលដែលមធ្យោបាយក្នុងការទំនាក់ទំនង ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងៗទៀតមានការខ្វះខាត លទ្ធភាពក្នុងការបោះទីតាំងធ្វើជំនួញរបស់បណ្តាក្រុមហ៊ុននានាក៏នៅមានកម្រិតផងដែរ។



កម្ពុជា ៤.0 Cambodia 4.0

**1970s:** ទោះបីជាអ៊ីម៉ែលត្រូវបានរកឃើញនៅឆ្នាំ 1971 ក៏ពិតមែនប៉ុន្តែវាហាក់ដូចជាពុំទទួលបានការចាប់អារម្មណ៍ពីបណ្ដាក្រុមហ៊ុននានានោះទេ ខណៈពួកគេផ្ដោតសំខាន់ទៅលើការស្វែងរកប្រាក់ចំណូលជាជាងការសាកល្បងបច្ចេកវិទ្យាថ្មីៗ។ ទោះជាយ៉ាងណាក៏ដោយ នៅអំឡុងទសវត្សរ៍នេះ មានការលេចចេញនូវបច្ចេកវិទ្យាថ្មីៗជាច្រើន រួមមាន daisy-wheel printer, floppy disk, និងហ្គេមវីដេអូដំបូងគេបង្អស់។



**1980s:** ជាមួយនឹងវត្តមាននៃក្រុមហ៊ុនបច្ចេកវិទ្យាខ្នាតយក្សមួយចំនួនដូចជា ក្រុមហ៊ុន IBM, Microsoft, Apple និងAT&T ការប្រើប្រាស់បច្ចេកវិទ្យានៅកន្លែងធ្វើការចាប់ផ្តើមទទួលបានការចាប់អារម្មណ៍។ កុំព្យូទ័រយួរដៃ (Laptop) ត្រូវបានបង្កើតឡើងនៅឆ្នាំ 1981 ហើយទូរស័ព្ទដៃដំបូងបង្អស់របស់ពិភពលោក ម៉ូឌែល Motorola DynaTAC 8000x ត្រូវបានដាក់លក់នៅឆ្នាំ1983។ ជាមួយនឹងឧបករណ៍ទំនាក់ទំនងថ្មីទាំងនេះ អាជីវកម្មនានាក៏ចាប់ផ្តើមមានលទ្ធភាព ពង្រីកវិសាលភាពនៃទីតាំងភូមិសាស្ត្រក្នុងការធ្វើជំនួញ។



កម្ពុជា ៤.0 - Cambodia 4.0

**1990s:** ជាមួយនឹងការកកើតឡើងនូវ World Wide Web នៅឆ្នាំ1989 បច្ចេកវិទ្យាកាន់តែមានសារៈសំខាន់។ ក្រុមហ៊ុននានាបានប្រើប្រាស់ Web សម្រាប់ការបង្ហាញអំពីផលិតផល និងសេវាកម្ម ក៏ដូចជាភ្ជាប់ទំនាក់ទំនងជាមួយអតិថិជន, អ្នកផ្គត់ផ្គង់, អ្នកផលិត និងអ្នកចែកចាយ។ លើសពីនេះទៅទៀត ដំណើរការទាំងនេះកាន់តែមានភាពងាយស្រួលខ្លាំងថែមមួយកម្រិតទៀត នៅពេល Google ត្រូវបានបង្កើតឡើងនៅឆ្នាំ1998។



**2000s:** Google ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយម្ចាស់អាជីវកម្ម និងអតិថិជននៅទូទាំងពិភពលោក។ ឧបករណ៍មួយចំនួនដូចជា Apple iPod, iPhone ត្រូវបានបង្កើតឡើង ហើយប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា Myspace និងFacebook ក៏បានចាប់ផ្ដើមលេចចេញជារូបរាងឡើង បន្ទាប់ពីអ៊ីនធឺណិតត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។ បច្ចុប្បន្ន អ្នកប្រើប្រាស់អាចស្វែងរក ឬទាក់ទងដៃគូអាជីវកម្ម ដែលអាចផ្ដល់ជាដំណោះស្រាយសម្រាប់បញ្ហារបស់ពួកគេ បើទោះបីជាពួកគេមិននៅជិតគ្នាក៏ដោយ។ ទន្ទឹមនេះ ម្ចាស់អាជីវកម្មអាចធ្វើការសិក្សាស្រាវជ្រាវអំពីអតិថិជនរបស់ពួកគេបានកាន់តែមានប្រសិទ្ធភាព ដើម្បីអាចបង្កើត ឬផ្គត់ផ្គង់ផលិតផលឱ្យកាន់តែស្របតាមតម្រូវការរបស់អតិថិជនគោលដៅ។

**2010s:** ការឈានមកដល់ដំណាក់កាលសម័យទំនើប ដែលបច្ចេកវិទ្យាបានជ្រៀតចូលយ៉ាងសកម្មនៅស្ទើរតែគ្រប់ផ្នែកទាំងអស់ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ក៏ដូចជាប្រតិបត្តិការអាជីវកម្ម។ និន្នាការក្នុងការចាប់យកការប្រើប្រាស់បច្ចេកវិទ្យានៅកន្លែងធ្វើការ ក៏ដូចជានៅតាមទីតាំងអាជីវកម្មបាននឹងកំពុងផ្លាស់ប្តូរឥតឈប់ឈរ ស្របតាមការវិវត្តយ៉ាងលឿននៃបច្ចេកវិទ្យាថ្មីៗ។

